**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

*ថ្ងៃសុក្រ ៦រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦*

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២*

# សេចក្តីជូនព័ត៌មាន

នាព្រឹកថ្ងៃសុក្រ ៦រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២ នៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា **ឯកឧត្តម រិត ទុទ្ធី** អគ្គលេខាធិការរង នៃគណៈកម្មាធិការនីតិសម្បទានិង អភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.នា/ក.អ.ក) បានទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយ**លោកស្រី Sandra Bernklau** តំណាងថ្មីនៃអង្គការ UNFPA ប្រចាំកម្ពុជា ។ **ឯកឧត្តមអគ្គលេខាធិការរង** បានទទួលស្វាគមន៍យ៉ាងកក់ក្តៅដល់**លោកស្រី Sandra Bernklau** និងអះអាងពីការប្តេជ្ញាចិត្ត និងការគាំទ្ររបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះលោកស្រី និងក្រុមការងារក្នុងអនុវត្តការងារអាទិភាពរបស់អង្គការ UNFPA ។

**ឯកឧត្តមអគ្គលេខាធិការរង** បានវាយតម្លៃខ្ពស់ទៅលើផែនការសកម្មភាពកម្មវិធីអភិវឌ្ឍន៍ប្រចាំប្រទេស ឆ្នាំ២០១៩-២០២៣ (Country Programme Action Plan-equivalent 2019-2023) ដែលបានរួមចំណែកយ៉ាងសំខាន់ដល់កិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព និងបរិយាបន្នកម្ពុជា និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អង្គការ UNFPA ក្នុងការអនុវត្តការងារនៃការអភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជាដោយផ្តោតសំខាន់ទៅលើការរៀបចំផែនការគ្រួសារ ការអប់រំផ្លូវភេទ និងការកាត់បន្ថយអំពើហិង្សាទៅលើស្ត្រី ជាពិសេសការជួយគាំទ្រទៅលើស្ត្រី និងកុមារីងាយរងគ្រោះ ។ ជុំវិញការរួមចំណែកក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៥ ក្នុងការកាត់បន្ថយអត្រាមរណភាពមាតាឱ្យត្រឹមយ៉ាងហោចណាស់ ៧៥ ភាគរយ ក្នុងកំឡុងឆ្នាំ១៩៩០-២០១៥ **ឯកឧត្តមអគ្គលេខាធិការរង** ក៏បានកោតសរសើរដល់អង្គការ UNFPA ប្រចាំកម្ពុជាដែលរួមចំណែកក្នុងការកាត់បន្ថយអត្រាមរណភាពមាតាជិតពីរភាគបី ដែលជាសមិទ្ធផលដល់ធំធេងដែលសម្រេចបានដោយប្រទេសចំនួន ៩ រួមទាំងប្រទេសកម្ពុជា ។

**លោកស្រី Sandra Bernklau** បានបង្ហាញសេចក្តីសោមនស្សរីករាយដែលបានមកបំពេញការងារជាតំណាងថ្មីនៃអង្គការ UNFPA ប្រចាំកម្ពុជា និងបានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូជាមួយ ក.អ.ក និងក្រសួង/ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា និងការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការសម្រេចបានវឌ្ឍនភាពនានាក្នុងការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចកម្ពុជា ។ ទន្ទឹមនឹងនេះ **លោកស្រី** បានបញ្ជាក់អំពីគោលជំហរយ៉ាងមុតមាំរបស់អង្គការ UNFPA ក្នុងការបន្តជួយគាំទ្ររាជរដ្ឋាភិបាលកម្ពុជាឱ្យសម្រេចបាននូវការងារអាទិភាពក្នុងកិច្ចអភិវឌ្ឍន៍ប្រទេស និងធានាថាកម្មវិធីអភិវឌ្ឍន៍ប្រចាំប្រទេសថ្មីរបស់អង្គការ UNFPA ដែលកំពុងរៀបចំ នឹងមានភាពបត់បែន ដើម្បីស្របតាមការងារអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ។ **លោកស្រី** ក៏បានស្នើសុំការណែនាំ និងការគាំទ្រពី គ.ជ.ន/ក.អ.ក ក្នុងការរៀបចំកម្មវិធីអភិវឌ្ឍន៍ប្រចាំប្រទេសថ្មីនេះផងដែរ ។

គួរបញ្ជាក់ផងដែរ ថវិកាប៉ាន់ស្មានក្នុងការអនុវត្តផែនការសកម្មភាពកម្មវិធីអភិវឌ្ឍន៍ប្រចាំប្រទេស ឆ្នាំ ២០១៩-២០២៣ មានចំនួនប្រមាណ **១៣ លានដុល្លារអាមេរិក** ដែលក្នុងនោះធនធានផ្ទាល់ខ្លួនដែលបានគ្រោងទុក មានចំនួនប្រមាណ **៨,៣ លានដុល្លារអាមេរិក** ។ យោងតាម ODA Database របស់គ.ជ.ន/ក.អ.ក អង្គការ UNFPA មានគម្រោងសរុបចំនួន **៩ គម្រោង** ក្នុងនោះគម្រោងចំនួន ៨ កំពុងអនុវត្ត និង **១** គម្រោងត្រូវបានបញ្ចប់ ។ ក្រសួងអនុវត្តសំខាន់ៗ រួមមាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី ក្រសួងសុខាភិបាល និងក្រសួងផែនការ ។

ជាកិច្ចបញ្ចប់ **ឯកឧត្តម វ៉ិត វុទ្ធី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការមូលនិធិប្រជាជនរបស់អង្គការសហប្រជាជាតិ (UNFPA) ប្រចាំកម្ពុជា ដែលបានបន្តគាំទ្រដល់ប្រទេសកម្ពុជា និងបានកោតសរសើរចំពោះកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងដ៏ជិតស្និទ្ធរវាងរាជរដ្ឋាភិបាលកម្ពុជា និង អង្គការ UNFPA ប្រចាំកម្ពុជា ។ **ឯកឧត្តមអគ្គលេខាធិការរង** និង**លោកស្រី Sandra Bernklau** បានសម្តែងការពេញចិត្តចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អរវាងកម្ពុជា និងអង្គការ UNFPA ប្រចាំកម្ពុជា ហើយបានប្តេជ្ញាចិត្តរួមគ្នាក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការដ៏ល្អបន្ថែមទៀត។